សង្ខេបសម្រាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ០៩

# អភិបាលកិច្ចអាងផ្ទៃរងទឹកភ្លៀង និងភាពស្មាក់ស្មើរក្នុងកិច្ចសហការៈ ករណីសិក្សានៅកម្ពុជា[១]

*ដោយ រស់ បណ្ដែត[២] លី តឹម[២] និង Anna THOMPSON[៣]*

## ខ្លឹមសារសំខាន់ៗ

- អាងផ្ទៃរងទឹកភ្លៀង ឬអាងទន្លេ សំដៅលើផ្ទៃដីដែលទឹកហូរឆ្លងកាត់មុនចូលដល់ទន្លេ ឬស្ទឹង។ ស្ថានភាពអាងទន្លេ អាស្រ័យលើធនធានដែលមាននៅក្នុងនោះ ដូចជា ទឹក ដី សត្វ និងរុក្ខជាតិ ដែលបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីសម្រាប់ទ្រទ្រង់ជីវចម្រុះក្នុងអាង។
- គោលនយោបាយ អភិបាលកិច្ចអាងផ្ទៃរងទឹកភ្លៀងបច្ចុប្បន្ន ផ្ដោតជាសំខាន់ទៅលើការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ ដែលត្រូវដាក់បញ្ចូលទៅក្នុងគោលនយោបាយនៃការគ្រប់គ្រងទឹកនៅកម្ពុជា ដើម្បីសម្រេចបាននូវការគ្រប់គ្រងធនធានទឹក ប្រកបដោយនិរន្តរភាព។ យុទ្ធសាស្ត្រនៃការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ បានទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហការរវាងអ្នកពាក់ព័ន្ធ ដោយផ្អែកលើលក្ខណៈជីវសាស្ត្រនៃធនធានទាំងឡាយនៅក្នុងអាង ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងលក្ខណៈដែលអាងទន្លេតែងឆ្លងកាត់ដែនរដ្ឋបាលជាច្រើន និងមានអ្នកប្រើប្រាស់ជាច្រើនក្រុមនៅក្នុងនោះ (Batchelor 1999)។
- គោលនយោបាយទឹកនៅកម្ពុជា បានទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសហការរវាងអ្នកពាក់ព័ន្ធ។ គោលនយោបាយនៃការអភិវឌ្ឍន៍ និងប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រប្រកបដោយការចូលរួម (PIMD) នៅឆ្នាំ ១៩៩៩ ផ្ដោតជាសំខាន់ ទៅលើការចូលរួមរបស់សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ប៉ុន្តែមិនសូវ ផ្ដោតទៅលើកិច្ចសហការរបស់មន្ទីរជំនាញនានាទេ (ឧ. វិស័យទឹក កសិកម្ម ព្រៃឈើ និងជលផល)។ ច្បាប់ទឹកឆ្នាំ២០០៧ ក៏បានលើកឡើងពីសារៈសំខាន់នៃកិច្ចសហការរវាងក្រសួង/មន្ទីរជំនាញ និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាលនានា ក្នុងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះដែរ (IWRM)។

## បញ្ហាចោទ

ការអនុវត្តយុទ្ធសាស្ត្រនៃ ការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ បង្ហាញពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ដើម្បីគ្រប់គ្រងអាងទន្លេនៅប្រទេសកម្ពុជា។ ការអនុវត្តវិធីសាស្ត្រនេះ ត្រូវមានកិច្ចសហការមិនត្រឹមតែរវាងកសិករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរវាងអ្នកពាក់ព័ន្ធពីគ្រប់វិស័យ និងអាជ្ញាធរក្នុងតំបន់ទៀតផង។ ដើម្បីសម្រេចបានកិច្ចសហការនេះ យុទ្ធសាស្ត្រនៃការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ តម្រូវឲ្យមានការរៀបចំស្ថាប័នអភិបាលកិច្ចថ្មីមួយហៅថា "គណៈកម្មាធិការគ្រប់គ្រងអាងទន្លេ" ដែលរួមបញ្ចូលទាំងភ្នាក់ងារ និងអ្នកពាក់ព័ន្ធជាច្រើនដែលចងក្រងគ្នាជារចនាសម្ព័ន្ធគ្រប់គ្រងមួយ (Abers & Keck 2006)។ យុទ្ធសាស្ត្រនៃការគ្រប់គ្រងអាងផ្ទៃរងទឹក

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ចងក្រងដោយ រស់-បណ្ដែត លី-តឹម និង Anna THOMPSON (ចេញផ្សាយក្នុងពេលខាងមុខ) មានចំណងជើងថា "*អភិបាលកិច្ចអាងផ្ទៃរងទឹកភ្លៀង និងភាពស្មាក់ស្មើរក្នុងកិច្ចសហការៈ ករណីសិក្សានៅកម្ពុជា*"។

២ កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ នៃវិទ្យាស្ថាន CDRI។

៣ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI។

ភ្លៀងចម្រុះ នឹងត្រូវដាក់បញ្ចូល ចំពេលដែលកម្ពុជាកំពុងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ[៤]។ គេមិនទាន់ដឹងច្បាស់ទេថា តើកសិករ អ្នកពាក់ព័ន្ធនៅតាមវិស័យនានា និងដែនរដ្ឋបាលក្នុងអាងនីមួយៗ អាចរួមសហការគ្នាបានដល់កម្រិតណា។ ការសិក្សានេះនឹងស្វែងរកនូវគម្លាត រវាងទ្រឹស្តីនៃការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ និងទិដ្ឋភាពជាក់ស្តែងនៃកិច្ចសហការរវាងអ្នកពាក់ព័ន្ធនៅកម្ពុជានាបច្ចុប្បន្ន ដើម្បីកំណត់រកវិធីសាស្ត្រធានាឲ្យការដាក់បញ្ចូលយុទ្ធសាស្ត្រថ្មីនេះ មានប្រសិទ្ធភាពល្អក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ករណីសិក្សា

ការស្រាវជ្រាវនេះ លើកយកប្រព័ន្ធស្ទឹងជ្រៃបាក់ក្នុងស្រុកទឹកផុស និងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ធ្វើជាករណីសិក្សា។ ប្រព័ន្ធស្ទឹងជ្រៃបាក់ត្រូវបានជ្រើសរើសដោយសារប្រព័ន្ធនេះ មាន សកបទ ជាច្រើនក្រុម និងការចូលរួមរបស់ភ្នាក់ងារបច្ចេកទេសស្រុក ខេត្ត និងអាជ្ញាធរដែនដី នៅក្នុងការងារគ្រប់គ្រងអាង។ ការស្រាវជ្រាវបែបគុណភាពនេះ អនុវត្តវិធីសាស្ត្រប្រមូលព័ត៌មានជាច្រើន ដូចជា ការសម្ភាសផ្ទាល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ការបង្កើតក្រុមពិភាក្សា និងការធ្វើអង្កេតដោយមានការចូលរួម។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

ការសិក្សានេះ រកឃើញថា កម្ពុជាក្នុងកម្រិតមួយ មានរចនាសម្ព័ន្ធអភិបាលកិច្ចរួចជាស្រេច សម្រាប់ធ្វើការគ្រប់គ្រងបញ្ហាអន្តរតំបន់ (ស្រដៀងគ្នានឹងបញ្ហាអាងផ្ទៃរងទឹកភ្លៀង) នៅឯថ្នាក់ឃុំ ស្រុក និងខេត្ត។ សាលាឃុំ ស្រុក និងខេត្ត កន្លងមកបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាអាងទន្លេ ជាពិសេសក្នុងអំឡុងពេលមានការខ្វះខាតទឹក ទោះជាតួនាទីនេះពុំទាន់ឆ្លើយតបបានពេញលេញទៅនឹងលក្ខខណ្ឌរបស់ "គណៈកម្មាធិការគ្រប់គ្រងអាងទន្លេ" ដែលបានកំណត់នៅក្នុងទ្រឹស្តីក៏ដោយ។ សាលាឃុំ ស្រុក និងខេត្ត មិនទាន់អាចដោះស្រាយបញ្ហាបច្ចេកទេសទាក់ទងអាងទន្លេបានទេ ហើយពួកគេត្រូវការកិច្ចសហការពីការិយាល័យ ឬមន្ទីរជំនាញ ដែលមានបច្ចេកទេស និងតួនាទី ក្នុងការគ្រប់គ្រងធនធានផ្សេងៗនៅក្នុងអាង ដូចបានកំណត់ដោយច្បាប់តាមវិស័យរបស់គេ។ ការបង្កើតឲ្យមានរដ្ឋបាលឯកភាពនៅថ្នាក់ស្រុក ខេត្ត ដោយច្បាប់រៀបចំអង្គការ[៥]ថ្មី បង្ហាញពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកៀងគរ និងបង្កើនកិច្ចសហការឡើងវិញរវាង សាលាស្រុក ខេត្ត ឃុំ និងការិយាល័យ ឬមន្ទីរជំនាញ។

ការសិក្សានេះ ក៏បង្ហាញដែរថា អ្នកពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ពុំសូវបានសហការគ្នាដើម្បីអនុវត្តការងារនៅក្នុងដែនអាងទន្លេនោះទេ ដោយសារកត្តាជាច្រើនដូចជា កត្តាវប្បធម៌ កង្វះទំនុកចិត្ត សិទ្ធិអំណាចជាន់គ្នា លក្ខណៈមជ្ឈការខ្លាំងពេក កង្វះសមត្ថភាព និងកង្វះព័ត៌មានស្តីអំពីព្រំសីមាដី កម្មសិទ្ធិដីធ្លី និងទឹក។ គម្រោងរបស់ម្ចាស់ជំនួយអាចជួយបង្កើនកិច្ចសហការរវាងមន្ទីរជំនាញក្នុងការធ្វើផែនការ និងអនុវត្តការងារ ប៉ុន្តែក៏មិនបានបិតថេរប៉ុន្មានដែរ ព្រោះអាស្រ័យទៅលើប្រាក់ជំនួយដែលមាន។

កត្តាវប្បធម៌៖ ទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធ នៅតែទទួលឥទ្ធិពលពីកត្តាវប្បធម៌ ដូចជា កសិករធ្វើទំនាក់ទំនងតែជាមួយញាតិសន្តាន និងអ្នកនៅក្នុងក្រុម ហើយការភ័យខ្លាចអាជ្ញាធរ ការមិនហ៊ានអះអាង និងទំនាក់ទំនងខ្សែខ្នងនៅតែឃើញមាន។ ទីមួយ កសិករខ្មែរធ្វើទំនាក់ទំនងតែជាមួយញាតិសន្តាន និងក្រុមមនុស្សក្នុងដែនសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។ កសិករមិនសូវទំនាក់ទំនងជាមួយក្រុមខាងក្រៅទេ លើកលែងតែក្នុងករណីចាំបាច់។ ការផ្តល់អំណោយជួយគ្នាទៅវិញទៅមក ឃើញមានមួយចំនួនក្នុងករណីសិក្សានេះ ប៉ុន្តែវាពុំបានជួយឲ្យមានកិច្ចសហការល្អរវាងកសិករពីប្រព័ន្ធមួយទៅប្រព័ន្ធមួយនោះទេ។ ទីពីរ កសិករនៅតែមានការភ័យខ្លាច និងមិនហ៊ានអះអាងនៅចំពោះមុខអាជ្ញាធរ។ កសិករតែងតែរង់ចាំឲ្យអាជ្ញាធរប្រាប់ពួកខ្លួនថា គួរទំនាក់ទំនង ឬចរចាជាមួយអ្នកខាងក្រៅ ឬធ្វើយ៉ាងណាវិញ។ ផ្នត់គំនិតបែបនេះ កើតចេញពីអារម្មណ៍ភ័យខ្លាចរបស់កសិករ ព្រោះពួកគាត់យល់ថា អាជ្ញាធរមានសិទ្ធិអំណាចជំទាស់ ឬកែប្រែ ប្រសិនបើពួកគាត់ធ្វើការងារដោយមិនមានការអនុញ្ញាតជាមុន។ ទីបី ទំនាក់ទំនងខ្សែខ្នង ក៏ឃើញមានច្រើនរូបភាពនៅក្នុងការងារមន្ទីរនីមួយៗ ជាពិសេសក្នុងពេលផ្តល់សេវាកម្ម ដូចជា អវត្តមានបុគ្គលិកក្នុងម៉ោងធ្វើការ ដោយមិនមានការពិន័យ កង្វះការអនុវត្តច្បាប់ចំពោះបុគ្គលិកដែលមិនបំពេញតួនាទី និងការយកកម្រៃក្រៅផ្លូវការពីប្រជាជន។

---

៤ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានគោលបំណងសម្រេចបាននូវអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅកម្ពុជា។ កម្មវិធីនេះចាប់ផ្តើមដំបូងដោយការធ្វើកំណែទម្រង់វិមជ្ឈការ តាមរយៈការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០២ ដើម្បីលើកកម្ពស់ការផ្តល់សេវាកម្មទៅដល់ប្រជាពលរដ្ឋ។ នៅឆ្នាំ២០០៩ កម្មវិធីនេះបានបន្តអនុវត្តលើកម្មវិធីកំណែទម្រង់វិសហមជ្ឈការដោយបង្កើតរដ្ឋបាលឯកភាពនៅថ្នាក់ស្រុកនិងខេត្ត ដើម្បីសម្របសម្រួលកិច្ចការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ។

៥ ច្បាប់រៀបចំអង្គការ ឆ្នាំ២០០៨ សំដៅលើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ទំនុកចិត្ត៖** កង្វះទំនុកចិត្ត ជាបញ្ហាចោទមួយទៀតនៅក្នុងសង្គមខ្មែរបច្ចុប្បន្ន ហើយក៏ជាមូលហេតុធ្វើឲ្យអ្នកពាក់ព័ន្ធនានាមិនព្រមសហការគ្នា។ កង្វះទំនុកចិត្តកើតឡើងរវាងក្រុមកសិករពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ និងរវាងអ្នកពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់។ ទីមួយ កង្វះទំនុកចិត្តរវាងក្រុមកសិករ កើតឡើងដោយសារកសិករនៅតាមអាងទន្លេផ្សេងៗមិនមានការឯកភាពគ្នា និងអត្តសញ្ញាណរួម។ ទីពីរ កង្វះទំនុកចិត្តរវាង សកបទ និងក្រុមប្រឹក្សាឃុំ បណ្តាលមកពី ១) ជម្លោះបុគ្គល ២) ការភ័ន្តច្រឡំកើតចេញពីសិទ្ធិអំណាចមិនច្បាស់លាស់ ឬជាន់គ្នា និង ៣) កង្វះតម្លាភាពក្នុងការគ្រប់គ្រងថវិកា។ ទីបី កង្វះទំនុកចិត្តរវាង សកបទ និងមន្ទីរជំនាញ កើតចេញពីការផ្តល់សេវាកម្មមិនទៀងទាត់របស់មន្ទីរ ការយកកម្រៃក្រៅផ្លូវការ និងការភ័ន្តច្រឡំរបស់កសិករលើសិទ្ធិប្រើប្រាស់ធនធាន។

**សិទ្ធិអំណាច៖** សិទ្ធិអំណាចដែលរួមមាន តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមួយចំនួន ដូចមានចែងនៅក្នុងច្បាប់ ឬគោលនយោបាយ គឺមានចំណុចជាន់គ្នា និងចន្លោះខ្វះខាត (ឧ. តួនាទីរបស់ សកបទ និងក្រុមប្រឹក្សាឃុំ ឬតួនាទីរបស់មន្ទីរជំនាញ)។ សិទ្ធិអំណាចជាន់គ្នាបែបនេះ នាំឲ្យមានការអនុវត្តការងារជាន់គ្នា និងគ្មានប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្ម។

**លក្ខណៈមជ្ឈការខ្លាំងពេក៖** មន្ទីរជំនាញនីមួយៗ ធ្វើផែនការ និងអនុវត្តការងារដាច់ដោយឡែកពីគ្នា។ ពួកគេបំពេញការងារឲ្យក្រសួងសាមីរៀងៗខ្លួន ពោលគឺមានលក្ខណៈមជ្ឈការខ្សែបណ្តោយខ្លាំងហួសពេក។

**កង្វះសមត្ថភាព៖** បញ្ហាសមត្ថភាពដែលរួមមាន កង្វះថវិកា បច្ចេកទេស និងជំនាញគ្រប់គ្រង ជាបញ្ហាចោទមួយទៀតដែលរារាំងកិច្ចសហការរវាងអ្នកពាក់ព័ន្ធ។ សកបទនានា តែងខ្វះខាតថវិកា ភាពជាអ្នកដឹកនាំ និងសិទ្ធិអំណាចក្នុងការកេណ្ឌប្រមូលកសិករ ដែលជាហេតុនាំឲ្យពួកគេត្រូវពឹងផ្អែកទៅលើក្រុមប្រឹក្សាឃុំ ដែលជាអ្នកមានលទ្ធភាពប្រមូលកសិករ និងមានបណ្តាញជាមួយអាជ្ញាធរស្រុក ក្នុងការសុំជំនួយពីខាងក្រៅ និងការធ្វើទំនាក់ទំនងជាមួយ សកបទ ដទៃ។ ទោះជាយ៉ាងនេះក្តី ក្រុមប្រឹក្សាឃុំពុំអាចផ្តល់ថវិកាឲ្យបានគ្រប់គ្រាន់ទៅដល់ សកបទ ដើម្បីជួយថែទាំប្រព័ន្ធស្រោចស្រពនោះទេ ដោយសារថវិកាឃុំ/សង្កាត់មានកំណត់ ដូច្នេះ សកបទ និងក្រុមប្រឹក្សាឃុំ ក៏ត្រូវពឹងផ្អែកទៅលើជំនួយគាំទ្ររបស់ អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ ឬសប្បុរសជនដែរ។ម្យ៉ាងទៀត កង្វះសមត្ថភាព ធ្វើឲ្យមន្ទីរជំនាញពុំមានកិច្ចសហការល្អជាមួយកសិករ។ បញ្ហាកង្វះសមត្ថភាពនេះ រួមមាន កង្វះបុគ្គលិក ប្រាក់បៀវត្សរ៍តិច កង្វះធនធានលើផ្នែកប្រតិបត្តិ សមត្ថភាពមន្ត្រីនៅមានកម្រិត តួនាទីរបស់មន្ត្រីនីមួយៗមិនទាន់ច្បាស់លាស់ និងកង្វះថវិកាអភិវឌ្ឍន៍។

**កង្វះព័ត៌មាន៖** អ្នកពាក់ព័ន្ធខ្វះព័ត៌មានស្តីអំពីព្រំសីមាដី កម្មសិទ្ធិដីធ្លី និងទឹក ដើម្បីអនុវត្តការងារ និងកិច្ចសហការ។

## បញ្ហាគួរពិចារណាសម្រាប់ការរៀបចំគោលនយោបាយជាតិ

តើលទ្ធផលនៃការសិក្សានេះ បានផ្តល់គំនិតអ្វីខ្លះសម្រាប់ ការអនុវត្តគោលនយោបាយនៃការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀង? ការសិក្សាបានបង្ហាញពីគម្លាតរវាងទ្រឹស្តីនៃការគ្រប់គ្រងអាងផ្ទៃរងទឹកភ្លៀងចម្រុះ និងទិដ្ឋភាពជាក់ស្តែងលើកិច្ចសហការរបស់អ្នកពាក់ព័ន្ធនៅកម្ពុជា។ តើគម្លាតនេះអាចបង្រួមយ៉ាងដូចម្តេចបាន? កន្លងមក មានសំណើមួយចំនួនដែលរាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់៖

### *១. ការពិចារណាលើការបង្កើត "គណៈកម្មាធិការគ្រប់គ្រងអាងទន្លេ"*

ក. ប្រសិនបើមានការបង្កើតនូវ គណៈកម្មាធិការអាងទន្លេមែន គេគួរដាក់បញ្ចូលទៅក្នុងប្រព័ន្ធអភិបាលកិច្ចដែលមានស្រាប់ ដូចបានកំណត់ក្នុងច្បាប់ឃុំ[៦] ច្បាប់រៀបចំអង្គការ និងច្បាប់តាមវិស័យផ្សេងៗ[៧] ដើម្បីចៀសវាងការជាន់តួនាទី ឬសិទ្ធិអំណាចគ្នា ដែលអាចបង្កជាទំនាស់ និងភាពតានតឹងរវាងស្ថាប័នក្នុងជួររដ្ឋាភិបាល។

ខ. ដោយសារលំហូរទឹកតែងឆ្លងកាត់ដែនរដ្ឋបាលជាច្រើន និងមានអ្នកពាក់ព័ន្ធច្រើន ដូច្នេះ គណៈកម្មាធិការអាងទន្លេដែលនឹងត្រូវបង្កើតឡើង ក៏គួរមានសមាសភាពចូលរួមច្រើនដែរ ក្នុងនេះ មានទាំងកសិករដែលត្រូវពឹងផ្អែកលើទឹក និងដី ដើម្បីទ្រទ្រង់ជីវិតផង។ គោលនយោបាយកំណែទម្រង់ ដែលសំដៅបង្កើតឲ្យមានគណៈកម្មាធិការអាងទន្លេនេះឡើង គួរកំណត់ឲ្យកសិករនៅមូលដ្ឋាន បានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ។

---

៦ ច្បាប់ឃុំឆ្នាំ២០០១ សំដៅលើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។

៧ ច្បាប់តាមវិស័យផ្សេងៗ សំដៅលើច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ របស់ក្រសួងធនធានទឹក និងឧតុនិយម ច្បាប់ស្តីពី ជលផលកម្ពុជា ឆ្នាំ២០០៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ច្បាប់ភូមិបាលឆ្នាំ២០០១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

### ២. *ដំណោះស្រាយថ្នាក់មូលដ្ឋានដើម្បីធានាឲ្យមានកិច្ចសហការអន្តរប្រព័ន្ធរវាងក្រុមកសិករ*

ក. ការសិក្សានេះបង្ហាញថា ទំនាក់ទំនងរបស់កសិករខ្មែរត្រូវបានកំណត់ដោយកត្តាវប្បធម៌។ ទំនាក់ទំនងក៏ទាមទារការចំណាយមួយចំនួនដែរ ហើយគេក៏មិនច្បាស់ដែរថា តើកសិករអាចរ៉ាប់រងវាបានបានឬទេ ដូច្នេះជំនួយគាំទ្រពីខាងក្រៅ មានសារៈសំខាន់នៅក្នុងកិច្ចការនេះ។ ជំនួយខាងក្រៅ គួរផ្តោតទៅលើការលើកកម្ពស់អត្តសញ្ញាណរួមរបស់កសិករ នៅតាមប្រព័ន្ធនានាក្នុងអាង តាមរយៈការបង្កើនចំណេះដឹងអំពីសារៈសំខាន់នៃកិច្ចសហការ ការបង្កើនបណ្តាញទំនាក់ទំនងពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ និងការផ្តល់ថវិកាជំនួយរដ្ឋបាល និងបច្ចេកទេស។

ខ. ដើម្បីធានាឲ្យមានកិច្ចសហការ ក្នុងការបែងចែកទឹកពីសហគមន៍មួយទៅសហគមន៍មួយ គេគួរអនុវត្តតាមវិធីសាមញ្ញ ដែលប្រជាកសិករបានកំណត់ដោយខ្លួនឯង។ ការស្រាវជ្រាវនេះរកឃើញថា កសិករចង់បាននូវការបែងចែកបន្ទុកចំណាយថែទាំប្រព័ន្ធរវាងអ្នកប្រើប្រាស់ទឹកផ្នែកខាងលើ និងអ្នកប្រើប្រាស់ផ្នែកខាងក្រោម ដើម្បីធានាឲ្យមានការចែករំលែកទឹកយ៉ាងប្រសើរពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ។

គ. ត្រូវលើកកម្ពស់សមត្ថភាពរបស់ សកបទ។ ដំណោះស្រាយមួយ គឺត្រូវពង្រឹងទំនាក់ទំនងរវាង សកបទ ជាមួយក្រុមប្រឹក្សាឃុំ ដោយត្រូវកំណត់ឲ្យមានគោលការណ៍ច្បាស់លាស់ថាតើ សកបទ និង ក្រុមប្រឹក្សាឃុំ គួរដាក់បញ្ចូលគំនិតយោបល់ និងការសម្រេចចិត្តរួមគ្នាយ៉ាងដូចម្តេច ដើម្បីធានាឲ្យមានការអភិវឌ្ឍល្អប្រសើរនៅថ្នាក់មូលដ្ឋាន។ មួយវិញទៀត ត្រូវធ្វើឲ្យមានតម្លាភាពក្នុងការគ្រប់គ្រងប្រាក់សេវារបស់ សកបទ និងត្រូវពិភាក្សាឡើងវិញអំពីដែនកំណត់ និងសិទ្ធិអំណាចដែល សកបទ អាចរកចំណូលនៅក្នុងដែនរដ្ឋបាលរបស់ឃុំ។

### ៣. *ដំណោះស្រាយថ្នាក់លើដើម្បីធានាឲ្យមានកិច្ចសហការ*

ក. ការសិក្សានេះ បានបង្ហាញពីសារៈសំខាន់នៃទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំនិងមន្ទីរជំនាញ និងរវាងមន្ទីរជំនាញនិងកសិករ ឬ សកបទ តាមរយៈការកសាងទំនុកចិត្ត ការរៀបចំឡើងវិញឲ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានា ការផ្តល់សេវាកម្មឲ្យបានល្អ និងការលុបបំបាត់ការយកកម្រៃក្រៅផ្លូវការ។ អ្នកពាក់ព័ន្ធនានាគួរតែសហការគ្នា ជាជាងរំលងលើគ្នា។

ខ. ការគ្រប់គ្រងអាងផ្ទេរងទឹកភ្លៀងចម្រុះ ពុំអាចទទួលជោគជ័យទេ ប្រសិនបើកម្មវិធីកំណែទម្រង់ដទៃទៀតមិនដំណើរការទៅមុខ ជាពិសេស កំណែទម្រង់វិសហមជ្ឈការ។

### ៤. *កត្តាចាំបាច់ផ្សេងៗ*

ក. ការគ្រប់គ្រងទឹកក្នុងអាងទន្លេ ពុំអាចអនុវត្តដាច់ដោយឡែកអំពីការគ្រប់គ្រងដី បរិស្ថាន ជលផល និងធនធានដទៃទៀត ដែលមាននៅក្នុងតំបន់អាងទន្លេនោះទេ។ ដើម្បីអនុវត្តការងារនេះ ត្រូវមាន៖

- ការបណ្តុះបណ្តាលដល់ សកបទ និងក្រុមប្រឹក្សាឃុំពីរបៀបធ្វើផែនការ សម្រាប់ការប្រើប្រាស់ទឹកតាមបែបចម្រុះនៅថ្នាក់មូលដ្ឋាន។
- ព័ត៌មានគ្រប់គ្រាន់ស្តីអំពីទឹក កម្មសិទ្ធិដីធ្លី និងព្រំសីមាដី (ឧ. កសិកម្ម ជលផល ព្រៃឈើ...)។
- ព័ត៌មានស្តីអំពីសិទ្ធិប្រើប្រាស់ធនធាន និង
- ការចុះបញ្ជីដីធ្លីយ៉ាងឆាប់រហ័ស ដើម្បីធានាឲ្យមានសំណុំបែបបទច្បាស់លាស់ ស្តីអំពីកម្មសិទ្ធិដីធ្លីឯកជន និងសាធារណៈ។

## ឯកសារយោង

Abers, R. N. & Keck, M. E. (2006), "Muddy Waters: The Political Construction of Deliberative River Basin Governance in Brazil", *International Journal of Urban and Regional Research*, 30(3), pp.601-22

Batchelor, C. (1999), "Improving Water Use Efficiency as Part of Integrated Catchment Management", *Agricultural Water Management*, 40, pp.249-263